ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០២ សណន

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៨

# សេចក្តីណែនាំបន្ថែម

# ស្តីពី

# ការពង្រឹងប្រសិទ្ធភាពយន្តការ " **ច្រកចេញ-ចូលតែមួយ** "

ដើម្បីសំរួលដល់ការចុះបញ្ជីវិនិយោគនៅតាមបណ្តាអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុងនិងដើម្បីពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ចអោយមានប្រសិទ្ធភាពខ្ពស់នោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំបន្ថែម និងកែសំរួលខ្លឹមសារសេចក្តីណែនាំលេខ ០៧ សរណន ចុះថ្ងៃ១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ដូចខាងក្រោម ៖

១. <u>ការធ្វើប្រតិភូកម្មអំណាចរបស់ក្រសួង-ស្ថាប័ន ជូនមន្ទីរ-អង្គភាពជាខ្សែបណ្តោយនៅតាមខេត្ត-ក្រុង</u>

គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវពិនិត្យឡើងវិញនូវខ្លឹមសារនៃលិខិតបទដ្ឋានស្តីពីការធ្វើប្រតិភូកម្មអំណាច ជូនមន្ទីរ-អង្គភាព ជាខ្សែបណ្តោយរបស់ខ្លួននៅតាមខេត្ត-ក្រុង អោយបានឆាប់ សំដៅធ្វើយ៉ាងណាអោយអនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង អាចដំណើរការប្រកបដោយប្រសិទ្ធភាពផង និងអាចធានាបាននូវការគ្រប់គ្រងផង ។ ការធ្វើប្រតិភូកម្មអំណាចកន្លងមក របស់បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធខ្លះ នៅមានកំរិតពុំអាចធ្វើអោយការដោះស្រាយការងារវិនិយោគនៅតាមខេត្ត-ក្រុងប្រព្រឹត្តិទៅដោយរលូននៅឡើយទេ ដោយក្រសួងខ្លះ ដូចជាក្រសួងទេសចរណ៍ជាដើម បានធ្វើប្រតិភូកម្មអំណាចជូនមន្ទីរទេសចរណ៍ ក្នុងកំរិតទាបបំផុត (ផ្ទះសំណាក់៥បន្ទប់-ផ្ទះសំណាក់ប៉ៅអ៊ីជាដើម) ហើយធ្វើបានតែចំពោះខេត្តសៀមរាប និងបាត់ដំបងប៉ុណ្ណោះ ។

ចំពោះក្រសួង-ស្ថាប័នណាមិនទាន់បានធ្វើប្រតិភូកម្មអំណាចជូនមន្ទីរ-អង្គភាព ជាខ្សែបណ្តោយរបស់ខ្លួន នៅតាមខេត្ត-ក្រុងនៅឡើយនោះ ត្រូវរួសរាន់បំពេញការងារនេះអោយបានឆាប់ ។

១. <u>ករណីដីសម្បទានសេដ្ឋកិច្ចទំហំក្រោម១.០០០ហិកតា:</u>

ដោយបញ្ហាដីធ្លីកំពុងស្ថិតក្នុងតំណាក់កាលកែទំរង់ និងស្មុគ្រស្មាញ ដោយមានទំនាស់ច្រើននោះ រាល់សំណើដីសម្បទានសេដ្ឋកិច្ច រួមទាំងដីដែលមានទំហំក្រោម១.០០០ហិកតា ដែលជាសិទ្ធសំរេចរបស់ខេត្ត-ក្រុងកន្លងមក ត្រូវស្ថិតក្រោមការសំរេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញ ។ ក្រោយពេលកំណែទំរង់ដីធ្លីត្រូវបានបញ្ចប់ ទើបពិនិត្យករណីធ្វើប្រតិភូកម្មអំណាចនូវសិទ្ធិសំរេចដីសម្បទានក្រោម១.០០០ហិកតា ជូនខេត្ត-ក្រុងវិញ ។

សេចក្តីណែនាំលេខ០៧ សរណន ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ដែលពុំមានខ្លឹមសារផ្ទុយពីសេចក្តីណែនាំបន្ថែមនេះ នៅមានសុពលភាពអនុវត្តដដែល ។

ក្រោយពីទទួលបានសេចក្តីណែនាំបន្ថែមនេះ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ គ្រប់ខេត្ត-ក្រុងទាំងអស់ មានភារកិច្ចសហការអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមងាសេនាបតីតេជោ ហ៊ុន សែន
  នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់ក្រសួង-ស្ថាប័ន " ដើម្បីអនុវត្ត "
- គ្រប់សមាជិក នៃក្រុមប្រឹក្សា។ភិវឌ្ឍន៍កម្ពុជា
- ឯកសារ-កាលប្បវត្តិ